# ការងារកសាងសន្តិភាព

*សេចក្តីអធិប្បាយពីវគ្គបណ្តុះបណ្តាលសំរាប់ឆ្នាំ២០១០*

## សេចក្តីសង្ខេបវគ្គសិក្សា

**ការងារកសាងសន្តិភាព** គឺជាកម្មវិធីមួយរបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។ គោលបំណងនៃវគ្គបណ្តុះបណ្តាលជំនាញខាងលើនេះ គឺដើម្បីបណ្តុះបណ្តាលអ្នកចូលរួមអោយបានយល់ដឹងអំពីជំនាញគ្រប់គ្រងទំនាស់ និងការកសាងសន្តិភាព ។ វគ្គបណ្តុះបណ្តាលនេះ នឹងត្រូវធ្វើឡើងជាភាសាខ្មែរ ចែកចេញជា៤វគ្គដោយក្នុងវគ្គនីមួយៗមានរយៈពេល៥ថ្ងៃ នៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។

*កម្មវិធីការងារកសាងសន្តិភាព* បានកើតមកពី *កម្មវិធីបណ្តុះបណ្តាលស្នូលអំពីជំនាញដោះស្រាយទំនាស់* ដែលបានរៀបចំឡើងដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីដោះស្រាយទំនាស់កាលពីឆ្នាំ១៩៩៧-៩៨ ក្នុងភាពជាដៃគូជាមួយអង្គការឆ្លើយតបទៅនឹងទំនាស់ / Responding to Conflict (ដែលជាអង្គការមួយមានទីស្នាក់ការនៅចក្រភពអង់គ្លេស ដែលមានជំនាញខាងការបណ្តុះបណ្តាលឯកទេសដោះស្រាយទំនាស់)។ វគ្គបណ្តុះបណ្តាលបច្ចុប្បន្ននេះបានធ្វើឡើងជាលើកដំបូងតាំងពីឆ្នាំ២០០១ និងមានលើកយកករណីសិក្សាជាច្រើន និងសេណារីយ៉ូដែលចោទជាបញ្ហាក្នុងបរិបទកម្ពុជាមកសិក្សា និងយកមកពិភាក្សាជាមួយគ្នា ហើយវគ្គនេះនឹងត្រូវបណ្តុះបណ្តាលដោយអ្នកអនុវត្តន៍ផ្ទាល់ / គ្រូបង្ហាត់កម្ពុជាមួយក្រុមដែលមានបទពិសោធន៍។ អ្នកសំរបសំរួលក្នុងវគ្គសិក្សានេះ សុទ្ធសឹងតែជាអ្នកដែលបានបញ្ចប់ *វគ្គសិក្សាកម្មវិធីស្នូលស្តីពីជំនាញដោះស្រាយទំនាស់* ដែលជាវគ្គដ៏សំខាន់មួយបានរៀបចំ និងសំរបសំរួលឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាលនិងអភិវឌ្ឍន៍កម្ពុជា។ សូមជំរាបផងដែរថា អ្នកសំរបសំរួលទាំងនោះ គឺជាគ្រូបង្ហាត់ដែលមានបទពិសោធន៍កម្មវិធីបណ្តុះបណ្តាលសន្តិភាពរបស់វិទ្យាស្ថាន និងអ្នកជំនាញឯកទេសមកពីខាងក្រៅ។

វគ្គបណ្តុះបណ្តាលនេះនឹងពិនិត្យពិចារណាលើទ្រឹស្តី និងការអនុវត្តន៍នៅពេលបច្ចុប្បន្ន ដូចដែលគេអនុវត្តលើការដោះស្រាយទំនាស់ដែលកំពុងកើតមានឡើងក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍន៍សមត្ថភាពបុគ្គល និងអង្គការ/ស្ថាប័នរបស់អ្នកចូលរួម។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីអភិវឌ្ឍន៍ និងគាំទ្រដល់សហគមន៍អ្នកធ្វើការងារគ្រប់គ្រងទំនាស់ និងការកសាងសន្តិភាពដោយផ្តល់នូវការបណ្តុះបណ្តាលជំនាញ និងធនធាន ព្រមទាំងបង្កើននូវសមត្ថភាពដល់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជាក្នុងការដោះស្រាយ គ្រប់គ្រង និង ការពារទំនាស់ផ្សេងៗដោយសន្តិវិធី ។

## ប្រធានបទសំខាន់ៗរួមមានដូចតទៅ:

- ក្របខណ្ឌ និងទ្រឹស្តីទំនាស់
- ឧបករណ៍សំរាប់វិភាគទំនាស់
- អំណាច និងទំនាស់
- ចរិតបុគ្គលនៅក្នុងទំនាស់ និង អន្តរាគមន៍ទំនាស់
- ដំណើរការដោះស្រាយទំនាស់ : ការចរចា និង ការសម្រុះសម្រួល
- ការកសាងសន្តិភាព និង ការកែប្រែទំនាស់
- តួនាទីអ្នកខាងក្នុង និង អ្នកខាងក្រៅ
- ជាតិនិយម : អត្តសញ្ញាណ និងជាតិពន្ធុ
- ជំនាញប្រាស្រ័យទាក់ទងក្នុងការដោះស្រាយទំនាស់
- ការផ្សះផ្សាឡើងវិញ
- ការកសាងទស្សនៈវិស័យនៅក្នុងអង្គការ ឬស្ថាប័ន
- ទំនាស់នៅក្នុងអង្គការ ឬស្ថាប័ន : ការដឹកនាំ ការកសាងក្រុម និង ការសំរេចចិត្ត

| ***កម្មវិធីសិក្សារួមមាន ៖*** | ***កាលបរិច្ឆេទ ៖*** |
|---|---|
| ១. ការយល់ដឹងអំពីទំនាស់ : ការវិភាគទំនាស់ | ០៧-១១ មិថុនា ២០១០ |
| ២. ការធ្វើអន្តរាគមន៍ទំនាស់ | ១២-១៦ កក្កដា ២០១០ |
| ៣. ការកសាងសន្តិភាព | ០៩-១៣ សីហា ២០១០ |
| ៤. សន្តិភាពក្នុងអង្គការ/ស្ថាប័នរបស់លោក-អ្នក | ០៦-១០ កញ្ញា ២០១០ |

## វគ្គសិក្សានេះបង្កើតឡើងសំរាប់នរណា?

អ្នកចូលរួមក្នុងវគ្គសិក្សានេះនឹងត្រូវជ្រើសរើសចេញមកពីស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងគោលបំណងសំរួលដល់ការសន្ទនា និងការយល់ដឹងអោយបានប្រសើរឡើងថែមទៀតរវាងផ្នែកផ្សេងៗក្នុងសង្គម។ អ្វីដែលមានសារៈសំខាន់បំផុតនោះ នឹងត្រូវផ្ដល់ទៅអោយអ្នកដឹកនាំសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការងារក្នុងការកសាងកម្ពុជាឡើងវិញ ដោយការពង្រឹងសង្គមស៊ីវិលតាមរយៈ ការអភិវឌ្ឍន៍ ការសង្គ្រោះ និងការងារកសាងសន្តិភាព។ ការបណ្ដុះបណ្ដាលនេះនឹងផ្ដល់អាទិភាពខ្ពស់ដល់បុគ្គលិកកម្មវិធីកម្ពុជានៃទីភ្នាក់ងារអន្តរជាតិ ព្រមទាំងបុគ្គលិក កម្មវិធីនៃទីភ្នាក់ងារជាដៃគូដែលមានការងារពាក់ព័ន្ធក្នុងសកម្មភាពគាំទ្រដោយផ្ទាល់ជាមួយនឹងអង្គការនិងសមាគមក្នុងស្រុក។ **ស្ត្រីត្រូវបានលើកទឹកចិត្តយ៉ាងពិសេសឱ្យដាក់ពាក្យក្នុងវគ្គសិក្សាទាំងនេះ** ។

សូមស្វាគមន៍នូវសំណូមពរ និងការគាំទ្ររបស់មន្ត្រីរាជរដ្ឋាភិបាល។ អាទិភាពនឹងត្រូវផ្ដល់ជូនដល់អ្នកដឹកនាំសហគមន៍ (ឃុំ និង សង្កាត់) និងប្រធាននាយកដ្ឋានទទួលបន្ទុកផ្នែកបណ្ដុះបណ្ដាល និងប្រធាននាយកដ្ឋានទទួលបន្ទុកបណ្ដុះបណ្ដាលធនធានមនុស្សតាមបណ្ដាក្រសួងនានាដូចជា: ក្រសួងមហាផ្ទៃ ក្រសួងដែនដីនគរូបនីយកម្មនិងសំណង់ រាជធានីភ្នំពេញ ក្រសួងការពារជាតិ ក្រសួងកសិកម្ម ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ព្រមទាំងដល់មន្ត្រីជាន់ខ្ពស់ ឬដៃគូសហប្រតិបត្តិការ ការងាររបស់គេនៅក៏រឹតមូលដ្ឋានផងដែរ ។

សូមជំរាបផងដែរថា វគ្គបណ្ដុះបណ្ដាលនេះ កំណត់ទទួលបេក្ខជនដែលមានលក្ខណៈសមស្របត្រឹមតែ ២៥នាក់ ប៉ុណ្ណោះ ហើយវិទ្យាស្ថានសូមលើកទឹកចិត្តលោក-អ្នកផ្ទាល់ដើម្បីដាក់ពាក្យសុំចូលរៀន។ រីឯកាលបរិច្ឆេទឈប់ទទួលពាក្យនៅថ្ងៃ **ព្រហស្បតិ៍ ទី ០១ ខែមេសា ឆ្នាំ២០១០** ។

## គោលបំណងនៃវគ្គសិក្សា

វិធីសាស្ត្របង្រៀន រចនាសម្ព័ន្ធ និងសកម្មភាពផ្សេងៗ ត្រូវបានប្រើក្នុងគោលបំណងអោយអ្នកចូលរួមអាចមើលឃើញនូវបញ្ហាផ្ទាល់របស់គេដែលទាក់ទិននឹងទំនុកចិត្ត ការទទួលយក និងការយល់ដឹងតាមរយៈការធ្វើការងារជាមួយអ្នកដទៃដែលមកពីមជ្ឈដ្ឋាន និងទិសដៅផ្សេងៗ ។ វគ្គបណ្ដុះបណ្ដាលនេះក៏ជាឱកាសមួយផងដែរ ដើម្បីមើលនូវការខ្វែងគំនិតគ្នា ដូចជាចំណុចចាប់ផ្ដើមសំរាប់ការដោះស្រាយបញ្ហា និង ការយោគយល់គ្នាទៅវិញទៅមកជាដើម ។ ជាពិសេសមានបំណងផ្ដល់អោយអ្នកចូលរួមនូវការយល់ដឹង :

- មូលដ្ឋានផ្នែកទ្រឹស្ដីដើម្បីយល់ដឹងនូវភាពស្មុគស្មាញនៃទំនាស់
- ឧបករណ៍សំរាប់ធ្វើការវិភាគលើការគ្រប់គ្រង និង អន្តរាគមន៍ទំនាស់
- ឱកាសសំរាប់ធ្វើការគិតពិចារណាទៅលើតួនាទីរបស់ពួកគេ ក្នុងការធ្វើអន្តរាគមន៍លើទំនាស់និងការកសាងសន្តិភាព
- មធ្យោបាយដើម្បីពិនិត្យឡើងវិញនូវជំនឿ ចរិត និង អាកប្បកិរិយា ដែលនាំទៅរកទំនាស់ ឬទៅរកសន្តិភាព
- សារៈសំខាន់នៃគោលការណ៍ដឹកនាំជាមូលដ្ឋាន
- អភិវឌ្ឍន៍ជំនាញនៃការប្រាស្រ័យទាក់ទង ជំនាញនៃការចរចា និង ជំនាញក្នុងការសម្រុះសម្រួល
- ការពិភាក្សាលើបញ្ហានៃការផ្សះផ្សាឡើងវិញ និងជាតិនិយម
- ការចងក្រងបណ្ដាញទំនាក់ទំនង

## វិធីសាស្ត្រនៃវគ្គសិក្សា

ការងារកសាងសន្តិភាព មានកម្មវិធីសិក្សា៤វគ្គជាប់ទាក់ទងគ្នាទៅវិញទៅមក និងរៀបចំឡើងដើម្បីបំពេញអោយគ្នាទៅវិញទៅមក។ វិធីសាស្ត្រនៃវគ្គសិក្សានេះ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក ដោយលើកយកការសិក្សាយ៉ាងល់អិតនូវវិធីសាស្ត្រផ្សេងៗ។ វិធីសាស្ត្រសិក្សាសំរាប់វគ្គនិមួយៗនឹងរួមបញ្ចូលនូវ ការធ្វើកិច្ចការប្រចាំវគ្គ លំហាត់អនុវត្ត និងទស្សនកិច្ចសិក្សា ដើម្បីអោយសិក្ខាកាមអាចភ្ជាប់ទ្រឹស្តីដែលបានសិក្សានៅក្នុងថ្នាក់រៀន ទៅនឹងការអនុវត្តជាក់ស្តែងនៅថ្នាក់មូលដ្ឋាន។

សិក្ខាសាលានេះនិងអញ្ជើញវាគ្មិន និងអ្នកជំនាញពីខាងក្រៅជាលក្ខណះបុគ្គល ឬ ជាក្រុម ដើម្បីបង្ហាញ នឹងចែករំលែកបទពិសោធន៍ទៅលើប្រធានបទជាក់លាក់ណាមួយ ដែលមានការទាក់ទងនិងមានសារះសំខាន់សំរាប់ការយល់ដឹងរបស់សិក្ខកាម ។

អ្នកចូលរួមត្រូវបានរំពឹងថារកមើល និងលើកយកករណីសិក្សាដោយផ្អែកលើបទពិសោធន៍ទំនាស់ផ្ទាល់របស់ ពួកគេមកពិភាក្សាក្នុងពេលបណ្តុះបណ្តាលហើយនឹងវាយតម្លៃប្រសិទ្ធិភាពនៃគំរូទស្សនះនិងទ្រឹស្តីដែលបានណែនាំបង្ហាញ។ អ្នកចូលរួមនឹងតម្រូវអោយចូលរួមទាំង៤វគ្គសិក្សា។ ក្រោយពេលបញ្ចប់វគ្គបណ្តុះ បណ្តាលនេះទៅអាចមានអ្នកបញ្ចប់វគ្គបណ្តុះបណ្តាលខ្លះនឹងត្រូវបានជ្រើសរើសអោយចូលរៀនវគ្គ *បណ្តុះបណ្តាលដើម្បីសន្តិភាព* ដែលជាវគ្គបណ្តុះបណ្តាលមួយមានលក្ខណៈទូលំទូលាយសំរាប់បង្ហាត់អោយក្លាយជាគ្រូហើយដែលវគ្គនេះ កម្មវិធីបណ្តុះបណ្តាលបានបង្ហាត់ចំនួន ៨វគ្គកន្លងរួចមកហើយដែរ ។

## មាតិកានៃវគ្គសិក្សា

ប្រធានបទសំខាន់ៗមានរៀបរាប់ដូចខាងក្រោម ប៉ុន្តែអាចផ្លាស់ប្តូរអាស្រ័យទៅលើតម្រូវការរបស់ក្រុម។ ទោះបីជាមាតិកាអាចខុសគ្នាពីការរៀបរាប់ខាងក្រោមក្តី ក៏គោលគំនិតមូលដ្ឋាន ជំនាញ និងដំណើរការនៅទាក់ទងគ្នាដដែល។
កម្មវិធីសិក្សាទាំង៤ រួមមាន :

### *១. ការយល់ដឹងពីទំនាស់: ការវិភាគទំនាស់: (រយៈពេល៥ថ្ងៃ)*

វគ្គសិក្សាដំបូងបង្កើតអោយមានជាមូលដ្ឋាន សំរាប់ការកសាងក្រុមសហប្រតិបត្តិការ ដើម្បីអាចនិយាយនិងស្តាប់គ្នាទៅវិញទៅមកព្រមទាំងផ្តល់នូវឧបករណ៏វិភាគ និងគំនិតដែលធ្លាប់បានប្រើដើម្បីរកអោយឃើញនូវ ទំនាស់សង្គម នយោបាយ និងទំនាស់បុគ្គល។ សារៈសំខាន់បំផុតគឺ ធ្វើអោយមានការគោរពគ្នាទៅវិញទៅមកក្នុងការដឹកនាំក្រុម និងការបង្កើតអោយមានជំនឿទុកចិត្តគ្នា ។ អ្នកចូលរួមនឹងបានប្រើប្រាស់ឧបករណ៍ដើម្បីវិភាគនូវបទពិសោធន៍ទំនាស់ផ្ទាល់របស់គេ និងករណីសិក្សានៅក្នុងសង្គមកម្ពុជាបន្ថែមទៀត។ វគ្គសិក្សា អភិវឌ្ឍន៏សមត្ថភាពបុគ្គលម្នាក់ៗ ដើម្បីប្រឈមមុខទៅនឹងភាពស្មុគស្មាញនៃស្ថានភាពទំនាស់នានា ។

*ប្រធានបទរួមមាន :*

- បទពិសោធន៏អំពីទំនាស់
- ការយល់ដឹងពីទំនាស់
- ទ្រឹស្តីនៃទំនាស់
- សន្តិសុខរបស់មនុស្ស
- សញ្ញាខន្ធ(ខ្សែពេលវេលា)
- ឧបករណ៏សំរាប់វិភាគទំនាស់ : ដំណាក់កាលទំនាស់ ការគូរផែនទី ត្រីកោណបទច ត្រីកោណពហុកំរិត ដើមឈើទំនាស់ និងចន្ទុលបញ្ហា

### *២. ការធ្វើអន្តរាគមន៍ : (រយៈពេល៥ថ្ងៃ )*

វគ្គសិក្សាទី២នេះផ្តល់ក្របខណ្ឌ និងបទពិសោធន៏ជាក់ស្តែងក្នុងបទអន្តរាគមន៏ដូចជា: ការចរចា ការសំរុះសំរួល និងបទពិសោធន៏ដំណោះគជ័យអំពីយុទ្ធសាស្ត្រក្នុងការ ទប់ស្កាត់ទំនាស់នៅពេលបោះឆ្នោត របស់កម្មវិធីទប់ស្កាត់ទំនាស់នៅពេល

បោះឆ្នោតនៃ CDRI ។ ការអនុវត្តន៍ផ្លូវការនិងក្រៅផ្លូវការនៃការសម្រុះសម្រួលនិងក្នុងប្រទេសកម្ពុជាត្រូវ លើកយកមកពិនិត្យរួមជាមួយនឹងការសង្កត់ធ្ងន់លើតួនាទីរបស់អ្នកសម្រុះសម្រួលផងដែរ ។ អ្នកចូលរួមនឹងមានឱកាសដើម្បី អនុវត្តនូវជំនាញសម្រុះសម្រួលដែលចេញមកពីបទពិសោធន៍ផ្ទាល់របស់គេដោយប្រើស្ថានភាពជាក់ស្តែងមួយនៃបទពិសោធន៍នោះ ។

*ប្រធានបទរួមមាន :*

- ទ្រឹស្តីអន្តរាគមន៍ទំនាស់
- ការណែនាំនៃការប្រាស្រ័យទាក់ទង
- ជំនាញប្រាស្រ័យទាក់ទងដើម្បីដោះស្រាយទំនាស់ : ការបរប្រយោគ ការសង្ខេប និងការរៀបចំប្រយោគឡើងវិញ ការស្តាប់ដោយយកចិត្តទុកដាក់ ការសួរសំណួរ
- ដំណើរការនៃការដោះស្រាយទំនាស់: ការចរចា និងការសំរុះសំរួល/ការផ្សះផ្សា

## ៣. ការកសាងសន្តិភាព: *(រយៈពេល៥ថ្ងៃ)*

វគ្គសិក្សានេះពិនិត្យមើលនូវរបៀបកសាងសន្តិភាពយូរអង្វែងតាមរយៈការគ្រប់គ្រងភាពតានតឹងផ្លូវចិត្ត និងការផ្សះផ្សាឡើងវិញ ។ អ្នកចូលរួមពិចារណានូវបញ្ហានៃអត្តសញ្ញាណផ្ទាល់របស់គេ និងវិធីសាស្ត្រឆ្លើយតបទៅនឹងទំនាស់ ហើយក៏ជាឱកាសសំរាប់ជនកម្ពុជា ដើម្បីពិនិត្យមើលនូវទស្សនះរបស់គេទៅលើប្រធានសំខាន់ៗដូចជា : ជាតិនិយម និងការផ្សះផ្សាឡើងវិញ។ អ្នកចូលរួមត្រូវស្នើឱ្យធ្វើការសង្កេតដោយខ្លួនឯង និងលទ្ធភាពផ្ទាល់ខ្លួនក្នុងការបត់បែនទៅតាម ស្ថានការណ៍ និងការផ្លាស់ប្តូរ។ វគ្គសិក្សាទី៣នេះ ពិភាក្សាផងដែរទៅលើគំនិតផ្តួចផ្តើមកសាងសន្តិភាពបែបអន្តរសាសនា។

*ប្រធានបទរួមមាន :*

- ការបង្ហាញពីការកសាងសន្តិភាព និង ការកែប្រែទំនាស់
- ការគ្រប់គ្រងភាពតានតឹងផ្លូវចិត្ត
- ការផ្សះផ្សាឡើងវិញ
- ចរិតបុគ្គលនៅក្នុងទំនាស់
- អត្តសញ្ញាណ និង កម្មសិទ្ធិ
- បញ្ហាសំរាប់អ្នកកសាងសន្តិភាពកម្ពុជា: ជាតិនិយម និងជាតិពន្ធ
- យេនឌ័រ និង ការកសាងសន្តិភាព
- វិធីសាស្ត្រកសាងសន្តិភាពតាមបែបអន្តរសាសនា (ករណីសិក្សាអំពីព្រះពុទ្ធជាអ្នកកសាងសន្តិភាព)

## ៤. សន្តិភាពក្នុងអង្គការ/ស្ថាប័នរបស់លោក-អ្នក: *(រយៈពេល៥ថ្ងៃ)*

វគ្គសិក្សាចុងក្រោយនេះផ្តោតសំខាន់ទៅលើភាពចាំបាច់ ដើម្បីធ្វើការកែប្រែ និងការកសាងសន្តិភាពដែលត្រូវចាប់ផ្តើមនៅកំរិតបុគ្គល និងអង្គការ/ស្ថាបន័ ហើយណែនាំអោយយល់នូវជំនាញក្នុងការធ្វើការងារជាក្រុម ការធ្វើសេចក្តីសំរេច ចិត្ត និងការដោះស្រាយបញ្ហារួមគ្នា។ បញ្ហានៃអភិបាលកិច្ច ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ត្រូវលើកយកមកពិចារណាដែលទាក់ទងទៅនឹងរបៀបនៃការចូលរួម និងឋានានុក្រម ។

*ប្រធានបទរួមមាន :*

- ការកសាងក្រុមការងារ
- ការសំរេចចិត្ត និង ការដោះស្រាយបញ្ហា
- តួនាទីអ្នកខាងក្នុង និង អ្នកខាងក្រៅ
- ទំនាស់នៅក្នុងអង្គការ/ស្ថាបន័
- យុទ្ធសាស្ត្រផ្តល់ និង ទទួលពត៌មានត្រលប់
- ភាពជាអ្នកដឹកនាំ
- ការកសាងទស្សនះវិស័យ

## ពាក្យសុំ តម្លៃសិក្សា និងអាហារូបករណ៍

អ្នកមានបំណងដាក់ពាក្យសុំចូលរៀន សូមបំពេញបែបបទដែលបានផ្តល់ជូន ។ កាលបរិច្ឆេទឈប់ទទួលពាក្យគឺ **ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០** បេក្ខជនណាដែលត្រូវបានពិនិត្យឃើញថាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងត្រូវបានអញ្ជើញមកសំភាសន៍នៅក្រោយកាលបរិច្ឆេទឈប់ទទួលពាក្យ ។

តម្លៃនៃវគ្គសិក្សាទាំងមូលគឺ ៥00 (ប្រាំរយ) ដុល្លារអាមេរិក រួមមានថ្លៃសិក្សា សំភារៈសិក្សា និងភេសជ្ជៈហើយតម្លៃនេះត្រូវបង់គ្រប់ចំនួនមុនវគ្គសិក្សាចាប់ផ្តើម ។ ចំនួននេះមិនអាចគ្រប់គ្រាន់សំរាប់ការចំណាយលើវគ្គសិក្សាទាំងមូល ទេ វិទ្យាស្ថាន CDRI ទទួលរ៉ាប់រងលើការចំណាយដែលនៅសល់នេះ។ រីឯការចំណាយផ្សេងៗដែលមិនបានរៀបរាប់ខាងលើគឺជាបន្ទុកផ្ទាល់របស់អ្នកចូលរួម ឬអង្គភាពរបស់អ្នកចូលរួម ។

យើងសូមស្វាគមន៍ចំពោះការគាំទ្រ និងការឧបត្ថម្ភរបស់និយោជក អង្គការ ឬស្ថាប័នរបស់លោក-អ្នកផ្ទាល់ និងទីភ្នាក់ងារដែលអង្គការរបស់លោក-អ្នកមានទំនាក់ទំនងការងារជាមួយ ក្នុងការផ្តល់មូលនិធិសំរាប់ការចូលរួមរបស់លោក- អ្នកក្នុងវគ្គសិក្សានេះ ។ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នឹងមានផ្តល់ការឧបត្ថម្ភអាហារូបករណ៍ខ្លះតាមដែលអាចធ្វើទៅបានសំរាប់ជួយដល់អ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តែគ្មានការជួយឧបត្ថម្ភគាំទ្រ ដើម្បីមកចូលរៀនវគ្គបណ្តុះបណ្តាលនេះ ហើយបុគ្គលដែលពុំមានការជួយគាំទ្រផ្នែកហិរញ្ញវត្ថុនោះត្រូវបំពេញបែបបទសុំអាហារូបករណ៍ដែលបានផ្តល់ជូន ។សូមអានពតិមានលើពាក្យសុំចូលរៀន និងពាក្យសុំអាហារូបករណ៍ដែលបានភ្ជាប់មកជាមួយនេះស្រាប់ ។

**សូមបញ្ជាក់: វគ្គសិក្សានេះមិនអនុញ្ញាតិអោយប្រើប្រាស់ទូរស័ព្ទពេលកំពុងសិក្សាឡើយ!**

សំរាប់ពតិមានបន្ថែម សូមមើល www.cdri.org.kh ឬទំនាក់ទំនងជាមួយ
លោកស្រី ហ៊ុយ រំដួល-ទូច វ៉ារីន និង ហួន ចន្ទ្រា
**នៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
តាមអាសយដ្ឋាន: CDRI ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ សង្កាត់បឹងកក់១ ទួលគោក ភ្នំពេញ
ប្រអប់សំបុត្រ ៦២២ ភ្នំពេញ ឬ CCC Box 18
ទូរស័ព្ទលេខ 0២៣ ៨៨១ ៩១៦
ឬតាមរយ: email: romduol@cdri.forum.org.kh ឬ chantrea@cdri.forum.org.kh